# ឥទ្ធិពលបណ្តាញសង្គមលើយុវជនខ្មែរ

*ដោយ* : **លោកស្រីបណ្ឌិត ជា វណ្ណី**
*ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រនិងយេនឌ័រ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*ក្នុងសម័យបច្ចុប្បន្ន បណ្តាញសង្គម* (Social Media) *ដូចជា ហ្វេសប៊ុក*(Facebook), *តិកតុ*(TikTok), *អ៊ីនស្តាក្រាម* (Instagram), *តេឡេក្រាម* (Telegram), *យូធូប* (YouTube).. *បានក្លាយជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃរបស់យុវជនខ្មែរ ពោលគឺយើងអាចនិយាយបានថា វាជាឧបករណ៍ទំនាក់ទំនងដ៏សំខាន់មួយដែលយុវជនខ្មែរជាច្រើនប្រើប្រាស់ជារៀងរាល់ថ្ងៃ និងជាវេទិកាដែលអនុញ្ញាតឱ្យយុវជនចែករំលែកនូវព័ត៌មាន បទពិសោធន៍ បង្ហាញអំពីទស្សនៈ ការយល់ឃើញ និងស្វែងរកចំណេះដឹងថ្មីៗ ដែលមានទាំងផ្នែកវិជ្ជមាន និងអវិជ្ជមាន ហើយដែលពេលខ្លះ វាអាចធ្វើឱ្យប៉ះពាល់ដល់សីលធម៌ ឥរិយាបទ និងទំនៀមទម្លាប់ប្រពៃណីខ្មែរផងដែរ។ ទោះយ៉ាងណាការប្រើប្រាស់បណ្តាញសង្គមដោយគ្មានការគ្រប់គ្រងឱ្យបានល្អ វានឹងអាចបណ្តាលឱ្យមានផលប៉ះពាល់អវិជ្ជមានដល់សីលធម៌ និងអត្តចរិតរបស់យុវជនផងដែរ។*

## ១. ផ្នែកវិជ្ជមាននៃបណ្តាញសង្គម

*បើតាមការសង្កេតជាទូទៅ បណ្តាញសង្គមដែលសព្វថ្ងៃស្ទើរតែត្រូវបានប្រើប្រាស់ដោយមនុស្សគ្រប់វ័យ ជាពិសេសយុវវ័យនោះ គឺមានចំណុចវិជ្ជមានដែលអាចជួយលើកស្ទួយចំណេះដឹងនិងចំណេះធ្វើក្នុងគ្រប់វិស័យ ទាំងសីលធម៌ វប្បធម៌ សាសនា សេដ្ឋកិច្ច សង្គមកិច្ច និងទាំងការអប់រំផងដែរ ដែលក្នុងនោះមានដូចជា៖*

**. ការផ្សព្វផ្សាយចំណេះដឹង និងព័ត៌មាន៖**

*បណ្តាញសង្គមបានចូលរួមបង្កើនចំណេះដឹង និងការយល់ដឹងពីសង្គម ការផ្សព្វផ្សាយព័ត៌មានបានរហ័ស ដោយ*

អនុញ្ញាតឱ្យមនុស្សទទួលបានព័ត៌មានថ្មីៗ និងការចែករំលែកព័ត៌មានសង្គមបានយ៉ាងលឿន និងយ៉ាងទូលំទូលាយ ហើយយុវជនក៏អាចពង្រីកចំណេះដឹងនិងពង្រឹងសមត្ថភាពបាន ដោយយុវជនអាចរៀនពីចំណេះនានាពី វប្បធម៌ ពីសីលធម៌ ពីសាសនា និងគុណតម្លៃជីវិតតាមរយៈគេហទំព័រ ឬគ្រូបង្រៀនតាមអ៊ីនធឺណិត។ ម្យ៉ាងវិញទៀតបណ្តាញសង្គមក៏អាចជាវេទិកាដែលបង្ហាញអំពីសមត្ថភាពសរសេរ និងសមត្ថភាពបញ្ចេញមតិយោបល់ ក៏ដូចជាការចែករំលែកព័ត៌មាន ដោយយុវជនអាចចូលរួមក្នុងក្រុមចំណាប់ចំណូលចិត្តនិងសកម្មភាពសង្គមតាមអនឡាញ និងការបង្ហោះមតិយោបល់យ៉ាងសុចរិតដែលអាចជួយបណ្តុះសីលធម៌នៃការគោរពគ្នា។

**. ជួយអភិវឌ្ឍការអប់រំ៖**

គ្រូ ក៏ដូចជាអ្នកជំនាញ និងអ្នកសិក្សាអាចប្រើបណ្តាញសង្គមសម្រាប់ចែករំលែកចំណេះដឹងតាម រយៈការសិក្សាអនឡាញដែលកំពុងតែពេញនិយមសម្រាប់អ្នកមិនសូវមានពេលវេលា ឬមធ្យោបាយគ្រប់គ្រាន់ក្នុងការធ្វើដំណើរទៅបង្រៀន ឬទៅទៅរៀនដោយផ្ទាល់ ឬក៏នៅឆ្ងាយពីគ្នាដែលមានការលំបាកឬឧបសគ្គដោយករណីប្រធានសក្តិករណីមានជំងឺធ្ងន់ ទឹកជំនន់ ហេតុការណ៍ផ្សេងៗជាដើម ការបង្រៀនអនឡាញតាមបណ្តាញសង្គមបានជួយសម្រួលដល់ផលវិបាកទាំងនោះបានច្រើន។

**. ការចែករំលែកគំនិតល្អៗ៖**

បណ្តាញសង្គមអាចជាវេទិកានាំយុវជនឱ្យបង្ហាញពីការចែករំលែកនូវគំនិតយោបល់ មតិល្អៗ គួបផ្សំនឹងការគោរព ការផ្តល់សេចក្តីអនុគ្រោះ និងសមត្ថភាពក្នុងការគិតវិជ្ជមាន ហើយយុវជនក៏អាចទទួលបានព័ត៌មានថ្មីៗទាក់ទងនឹងសង្គម វប្បធម៌ និងការអប់រំដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ។

**. ការចូលរួមក្នុងសង្គម៖**

យុវជនអាចចូលរួមក្នុងសកម្មភាពនានារបស់សង្គមដែលមានគុណតម្លៃ ដូចជាការធ្វើសប្បុរសធម៌ ការបរិច្ចាគនូវសម្ភារៈថវិកា ពេលវេលា កម្លាំងកាយ កម្លាំងចិត្តក្នុងការជួយគ្នា ការអភិវឌ្ឍសហគមន៍ តាមរយៈប្រព័ន្ធបណ្តាញសង្គមបានរហ័ស ហើយក៏អាចជួយបង្កើនការយល់ដឹងអំពីសិទ្ធិ

មនុស្សនិងបញ្ហានានាដែលកើតមានឡើង ក្នុងសង្គម ក៏ដូចជានៅក្នុងពិភពលោក។

**. ជួយបង្កើតសមត្ថភាពទំនាក់ទំនង និងភាពជាអ្នកដឹកនាំ៖**

បណ្ដាញសង្គមនឹងដើរតួនាទីសំខាន់ ដែលអនុញ្ញាតឱ្យមនុស្សមានទំនាក់ទំនងជាមួយមិត្តភក្តិ មិត្តរួមការងារ ឬមនុស្សថ្មីៗបានយ៉ាងឆាប់រហ័ស និងជួយអភិវឌ្ឍសមត្ថភាពជំនាញទំនាក់ទំនងអនឡាញ ដូចជា ការបង្ហាញគំនិត ការស្ដាប់ និងការបញ្ចេញមតិឆ្លើយតបប្រកបដោយសុជីវធម៌។ យុវជនអាចបង្ហាញនូវសមត្ថភាពដឹកនាំតាមរយៈការចែករំលែកគំនិតល្អៗ ឬការបង្កើតសហគមន៍អនឡាញ ដែលជាវិធីសាស្ត្រដើម្បីបណ្ដុះជំនាញក្នុងការគ្រប់គ្រងក្រុម ធ្វើការជាអ្នកណែនាំ ឬបង្កើននូវឥទ្ធិពលលើអ្នកដទៃក៏ដូចជាមធ្យោបាយបណ្ដុះភាពទំនួលខុសត្រូវ និងការច្នៃប្រឌិតក្នុងការដឹកនាំគម្រោងឬសកម្មភាពនានាក្នុងសង្គម។

**. ជាវិធីសាស្ត្រអប់រំថ្មី៖**

ក្នុងបណ្ដាញសង្គមជារឿយៗយើងតែងតែសង្កេតឃើញមានការផលិតមាតិកាវីដេអូ ឬអត្ថបទអប់រំខ្លីៗ ដែលអាចចូលរួមចំណែកជួយលើកកម្ពស់សីលធម៌ និងគុណធម៌សង្គមបានយ៉ាងទូលំទូលាយ។

**. លើកកម្ពស់សេដ្ឋកិច្ចជាតិ៖**

មិនថាអាជីវកម្មតូចឬធំនោះទេ គឺគេអាចប្រើប្រាស់ បណ្ដាញសង្គមសម្រាប់ផ្សព្វផ្សាយនូវរាល់ផលិតផលនិងសេវាកម្មដែលជាការផ្ដល់ ឱកាសឱ្យអាជីវកម្ម ឬបុគ្គលអាចភ្ជាប់ទៅកាន់អតិថិជនបានយ៉ាងរហ័សនិងយ៉ាងទូលំទូលាយ ហើយប្រសើរជាងមុន ឧទាហរណ៍ដូចជា ហ្វេសប៊ុក (Facebook) ស័ក្តិសមសម្រាប់អាជីវកម្មគ្រប់ប្រភេទ ដើម្បីបង្ហាញពីផលិតផល ដោយអាចធ្វើជាវីដេអូផ្សាយផ្ទាល់ (Live) និងបង្ហាញពាណិជ្ជកម្មតាមរយៈ Group ជាដើម។

## ២. ផ្នែកអវិជ្ជមាននៃបណ្ដាញសង្គម

ទោះបីជាបណ្ដាញសង្គមមានអត្ថប្រយោជន៍ច្រើនយ៉ាងក្ដី ក៏បណ្ដាញសង្គមអាចមានឥទ្ធិពលជាអវិជ្ជមានលើយុវជនផងដែរដូចជា៖

**. ប៉ះពាល់ដល់សុខភាពផ្លូវចិត្ត៖**

ការតាមដាន ឬពឹងផ្អែកពេកលើបណ្ដាញសង្គម ធ្វើឱ្យខាតពេលវេលា មាន

ភាពរំខានក្នុងការគេង និងរំខានការសិក្សា ធ្វើឱ្យលទ្ធផលនៃការសិក្សាមិនបានប្រសើរ និងពេលខ្លះមានអារម្មណ៍តានតឹង បាត់បង់ចំណង់អាហារ បាត់បង់ការទំនាក់ទំនងផ្ទាល់ជាមួយគ្រួសារ ក៏ដូចជាមួយសង្គម។ ម្យ៉ាងវិញទៀត ពេលខ្លះបណ្ដាញសង្គមធ្វើឱ្យយើងមានការប្រៀបធៀបខ្លួនឯងជាមួយអ្នកដទៃដែលគេបានបង្ហាញពីភាពជោគជ័យ ឬពីភាពមានបានដែលអ្នកខ្លះចេះតែសម្ដែងឱ្យឃើញល្អ ឱ្យឃើញឡូយឆាយ ដែលអាចបណ្ដាលឱ្យមានអារម្មណ៍ថាតម្លៃខ្លួនទាប ឬអស់ទំនុកចិត្តលើខ្លួនឯង និងជួនកាលឈានទៅរកការគិតខ្លីសម្លាប់ខ្លួនក៏មាន។

**. បាត់បង់ពេលវេលានិងផលិតភាព៖**

មនុស្សជាច្រើនចំណាយពេលរាប់ម៉ោងក្នុងមួយថ្ងៃៗទៅលើបណ្ដាញសង្គម ដោយគ្មានគោលបំណងច្បាស់លាស់ ដែលបណ្ដាលឱ្យការសិក្សាឬការងារត្រូវខកខាន ឬមានភាពរអាក់រអួល។ ប្រសិនបើយើងមិនគ្រប់គ្រងការប្រើប្រាស់វាឱ្យបានល្អសមរម្យទេនោះ វាអាចជាការចំណាយពេលវេលាដោយឥតប្រយោជន៍ និងជាការរំខានដល់ផលិតភាពការងាររបស់យើង។

**. ទទួលបានព័ត៌មានមិនពិត និងការផ្សព្វផ្សាយមតិយោបល់មិនត្រឹមត្រូវ៖**

មានការចែករំលែកព័ត៌មានមិនត្រឹមត្រូវ ឬពត៌មានក្លែងក្លាយ ដែលអាចបង្កការយល់ច្រឡំក្នុងសង្គម។ ការរីករាលដាលព័ត៌មានមិនពិត ធ្វើឱ្យមានការយល់ច្រឡំ លែងមានទំនុកចិត្តលើព័ត៌មាន (ព័ត៌មានពិតលែងជឿ ព័ត៌មានមិនពិតក៏ជឿ) និងបង្កឱ្យមានចលាចលក្នុងសង្គម និងមានឥរិយាបទមិនសមរម្យ។

**. រំលោភឯកជនភាព និងការរំលោភបំពានតាមអ៊ីនធឺណិត៖**

នៅក្នុងការប្រើប្រាស់បណ្ដាញសង្គមដោយខ្វះនូវការពិចារណា ព័ត៌មានផ្ទាល់ខ្លួនរបស់យើងអាចប្រឈមនឹងហានិភ័យ ឬក៏ត្រូវបានគេលួចប្រើប្រាស់ដោយគ្មានការអនុញ្ញាត ដូចជាការលួចទិន្នន័យតាមរយៈ សកម្មភាព និងការទំនាក់ទំនង (ការបង្ហាញពីទីលំនៅ, លេខទូរស័ព្ទ, ឯកសារផ្ទាល់ខ្លួន ឬរូបភាពទំនាក់ទំនងក្រុមគ្រួសារ) ដែលអាចឈានទៅដល់ការបោកប្រាស់តាមអនឡាញ និងធ្វើឱ្យអ្នកប្រើប្រាស់ខ្លះមានអារម្មណ៍ថាខ្លួនដូចជាត្រូវបានបំពានឬប៉ះពាល់ ជា

*ពិសេសការចុចលើតំណភ្ជាប់ផ្សេងៗដែលយើងមិនបានដឹងប្រភពច្បាស់និងគួរឱ្យសង្ស័យ ដែលអាចនាំឱ្យគេបញ្ចូលមេរោគ ឬលួចទិន្នន័យផ្ទាល់ខ្លួនរបស់យើង។*

. **ការពង្រីកអំពើអសីលធម៌៖**

*អំពើអសីលធម៌មានដូចជា ការបង្ហោះរូបភាព ឬ វីដេអូមិនសមរម្យ ការបង្ហោះពាក្យប្រមាថ ឬការទម្លាក់តម្លៃអ្នកដទៃនិងសង្គមជាតិ និងបង្កការរអាក់រអួលក្នុងទំនាក់ទំនងពិត ដែលមនុស្សខ្លះចូលចិត្តស្ថិតនៅលើអ៊ីនធឺណិតជាងជួបមុខគ្នាដែលអាចបណ្ដាលឱ្យបាត់បង់នូវជំនឿ និងអារម្មណ៍ស្និទ្ធស្នាលក្នុងជីវិតពិត។*

. **ផលប៉ះពាល់នៃការទទួលវប្បធម៌បរទេស៖**

*បណ្ដាញសង្គមជាបណ្ដាញមួយដែលមានលក្ខណៈទូលំទូលាយ ដ្បិតជាបណ្ដាញមួយដែលត្រូវបានប្រើប្រាស់ដោយប្រទេសជាច្រើននៅលើសាកលលោក ដែលអាចធ្វើឱ្យយុវជនខ្មែរមួយចំនួនឆាប់ទទួលយកដោយខ្វះការពិចារណា ឆាប់ចម្លងតាមវប្បធម៌បរទេសមិនសមនឹងសង្គមខ្មែរ ដែលធ្វើឱ្យមានការប៉ះពាល់ដល់ប្រពៃណីទំនៀមទម្លាប់ខ្មែរ ដូចជា វប្បធម៌* “freedom” *ដែលលើសកម្រិត បញ្ហាសីលធម៌ និងអាកប្បកិរិយាមិនសមរម្យ ការចែករំលែកមាតិកាមិនសមរម្យ ឬនិន្នាការសម្លៀកបំពាក់បែបល្បីល្បាញដែលប៉ះពាល់ដល់សង្គម និងធ្វើឱ្យបាត់បង់នូវអត្តសញ្ញាណវប្បធម៌ជាតិ។*

## ៣. ដំណោះស្រាយ និងអនុសាសន៍

*ដើម្បីរក្សាបាននូវសីលធម៌ ប្រពៃណីទំនៀមទម្លាប់ល្អនៃយុវជនខ្មែរក្នុងបច្ចុប្បន្នភាពនៃយុគបណ្ដាញសង្គម យើងត្រូវ៖*

*. បង្កើនការអប់រំសីលធម៌ និងការស្វែងយល់ពីតម្លៃនៃវប្បធម៌ខ្លួនជាខ្មែរ ពោលគឺបង្រៀនបន្ថែមអំពីប្រកបដោយសីលធម៌តាមសាលារៀន ក៏ដូចជាគ្រួសារ និងសង្គម ដោយផ្ដែកលើសីលធម៌ សុជីវធម៌ គុណធម៌នៃបុរាណខ្មែរ (ការគោរពឪពុកម្ដាយ គ្រូបង្រៀន មនុស្សចាស់ជរា ការអត់ធ្មត់ សុភាពរាបសារ និងការស្រឡាញ់ជាតិ) ជាពិសេសប្រើប្រព័ន្ធបណ្ដាញសង្គមដើម្បីចែករំលែកខ្លឹមសារអប់រំសីលធម៌។ ក្រៅពីនោះ សហគមន៍ និងអាជ្ញាធរ ក៏គួរជួយជំរុញការផ្សព្វផ្សាយអំពីសីលធម៌ និងការគោរពច្បាប់ទម្លាប់ផងដែរ ដ្បិតថាការរក្សាសីលធម៌*

ល្អក្នុងយុគបណ្តាញសង្គម គឺចាប់ផ្តើមពីការអប់រំគ្រួសារ ការបង្ហាត់ខ្លួនឯង និងការប្រើប្រាស់បច្ចេកវិទ្យាដោយមានការយល់ដឹង និងទំនួលខុសត្រូវ។

. បង្រៀនយុវជនឱ្យប្រើបណ្តាញសង្គមដោយឆ្លាតវៃ គឺទាំងឪពុកម្តាយ និងទាំងគ្រូបង្រៀន ត្រូវចេះជួយណែនាំដល់កូនៗ និងសិស្ស-និស្សិត ជាពិសេសយុវជន អំពីការប្រើប្រាស់បណ្តាញសង្គមឱ្យបានត្រឹមត្រូវ និងប្រកបដោយទំនួលខុសត្រូវ ដោយរៀនកំណត់ពេលវេលាក្នុងការប្រើនូវអ៊ីនធឺណិត ដើម្បីជៀសវាងការជក់ចិត្តរហូតដល់ញៀនបណ្តាញសង្គម។

. គិតជាមុនសិនមុននឹងចែករំលែក ឬសរសេរអ្វីៗនៅលើអ៊ីនធឺណិត ដោយឈរលើគោលការណ៍គោរពនិងផ្តល់តម្លៃចំពោះអ្នកដទៃ មិនប្រើពាក្យអសុរស ពាក្យបន្ទោស ពាក្យបណ្តោរ បន្ទុះបង្អាប់ ឬបង្ហោះអ្វីដែលប៉ះពាល់អ្នកដទៃ) និងត្រូវចេះប្រើប្រាស់បណ្តាញសង្គមយ៉ាងមានគំនិត និងគោរពលើគោលនៃសីលធម៌ខ្មែរ មានន័យថាត្រូវមានវិន័យក្នុងការជ្រើសរើសព័ត៌មានឱ្យបានត្រឹមត្រូវមុននឹងធ្វើការចែករំលែកដោយត្រូវចេះសួរខ្លួនឯងជាមុន ហើយឈរលើគោលការណ៍ពិចារណា ថាតើគួរចែករំលែកឬមិនគួរចែករំលែក?។

. រៀនកំណត់អត្តសញ្ញាណឌីជីថល (Digital Identity) ឱ្យមានសុវត្ថិភាព និងមានតម្លាភាពល្អ។

. មានការចូលរួមពីគ្រួសារ សាលារៀន និងសង្គម គឺគ្រួសារគួរជាគំរូល្អដល់កូន ធ្វើឱ្យកូនយល់ពីតម្លៃសីលធម៌ សាលារៀន និងសង្គម គួរបង្កើនកម្មវិធីអប់រំសីលធម៌។

. ចូលរួមក្នុងសកម្មភាពសង្គម ដែលយុវជនគួរចូលរួមស្ម័គ្រចិត្តឧបត្ថម្ភសង្គម ឬអភិវឌ្ឍសហគមន៍ ដើម្បីបណ្តុះគុណធម៌នៃការសហការ និងចិត្តមេត្តា។

. បង្កើនការយល់ដឹងអំពីវប្បធម៌ជាតិ យល់ដឹងពីប្រវត្តិសាស្ត្រ និងវប្បធម៌ខ្មែរ ដើម្បីបង្កើនមោទនភាពជាតិ និងការគោរពខ្លួនឯង ក៏ដូចជាអ្នកដទៃ។

. សាលារៀននិងស្ថាប័នអប់រំ គួរបញ្ចូលមេរៀនអំពីការប្រើបណ្តាញសង្គមដោយសុវត្ថិភាព និងសីលធម៌ ដោយពន្យល់ណែនាំអំពីផលប៉ះពាល់នៃការប្រើប្រាស់

បណ្តាញសង្គមដូចជា ការប្រើប្រាស់នូវបណ្តាញសង្គមមិនត្រឹមត្រូវអាចប៉ះពាល់ដល់ឯកជនភាពរបស់បុគ្គល ឬបណ្តាលឱ្យមានការយល់ច្រឡំ។

. រដ្ឋាភិបាលនិងស្ថាប័នសារព័ត៌មានគួរបង្កើនបន្ថែមនូវការផ្សព្វផ្សាយកម្មវិធីអប់រំតាមប្រព័ន្ធអនឡាញ និងច្បាប់ទាក់ទងនឹងការប្រើប្រាស់បណ្តាញសង្គម។

## សេចក្តីសន្និដ្ឋាន

ជារួមបណ្តាញសង្គម គឺជាឧបករណ៍សម័យថ្មីដែលមានអត្ថប្រយោជន៍យ៉ាងច្រើនក្នុងការជួយអភិវឌ្ឍន៍សង្គម ប្រសិនបើយុវជនចេះប្រើវាប្រកបដោយគុណតម្លៃ និងមានសីលធម៌ ពោលគឺការចេះទាញយកសារប្រយោជន៍ពីបណ្តាញសង្គម។ វាមិនត្រឹមតែជាវិធីសាស្ត្រប្រាស្រ័យទាក់ទងនោះទេ ប៉ុន្តែជាវេទិកាដ៏មានអំណាចសម្រាប់ការផ្លាស់ប្តូរព័ត៌មាន ការអប់រំ ការអភិវឌ្ឍនូវសេដ្ឋកិច្ចជាតិ និងវប្បធម៌នៃសង្គមផងដែរ ហើយក៏ជាការលើកទឹកចិត្តសហគមន៍ និងស្មារតីសាធារណៈ ដែលបណ្តាញសង្គមអាចជួយដល់ការរួមចំណែកសង្គម ដូចជាការធ្វើសប្បុរសធម៌ ការចេះជួយគ្នា ការផ្តល់ព័ត៌មានដល់គ្នា ឬការពង្រឹងសិទ្ធិមនុស្ស និងជាពិសេសការចេះច្នៃប្រឌិត និងចេះបង្កើតអត្តសញ្ញាណឌីជីថល ដែលជាគន្លងមួយជួយឱ្យយុវជនអាចបង្ហាញពីសមត្ថភាព និងគំនិតថ្មីៗ។ ប៉ុន្តែប្រសិនបើយុវជនប្រើប្រាស់បណ្តាញសង្គមដោយខ្វះការពិចារណា និងគ្មានការយកចិត្តទុកដាក់ទេនោះ វានឹងអាចនាំឱ្យមានផលប៉ះពាល់ទាំងសីលធម៌ និងវប្បធម៌ខ្មែរ នឹងរងផលប៉ះពាល់ធ្ងន់ធ្ងរចំពោះខ្លួនឯង គ្រួសារ សហគមន៍ និងសង្គមជាតិផងដែរ។ ទោះជាយ៉ាងណា ការប្រើប្រាស់បណ្តាញសង្គមឱ្យមានប្រសិទ្ធភាព វាចាំបាច់ត្រូវការនូវសមធម៌ និងការយកចិត្តទុកដាក់ខ្ពស់ ដើម្បីជៀសវាងបញ្ហាដូចជាព័ត៌មានមិនត្រឹមត្រូវ ឬការប៉ះពាល់ផ្លូវចិត្ត ប៉ះពាល់ដល់ការអភិវឌ្ឍសង្គមជាតិផងដែរ។

ដូច្នេះយុវជនគ្រប់រូបគួរប្រើបណ្តាញសង្គមយ៉ាងណាប្រកបដោយការទទួលខុសត្រូវ និងរក្សាបានភាពល្អនៃសង្គមខ្មែរ។ យុវជនគួរចេះពិនិត្យប្រភពព័ត៌មានជាមុនមុនផ្សព្វផ្សាយ កុំចែករំលែកព័ត៌មានដែលមិនពិតដាក់ស្តែង ឬមិនមានការបញ្ជាក់អំពីប្រភពច្បាស់លាស់។ យុវជនគួរជួយរារាំងការផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ ដែលអាច

បង្កភាពច្របូកច្របល់ក្នុងសង្គម។ យុវជនគួរចងចាំថា ការគោរពគ្នាទៅវិញទៅមកបង្កើនគុណធម៌ និងភាពរួបរួមក្នុងសង្គមជាតិ។ យុវជនគួរចេះការពារភាពឯកជនភាពរបស់ខ្លួនឯង និងអ្នកដទៃកុំបង្ហាញព័ត៌មានផ្ទាល់ខ្លួនច្រើនពេក (ដូចជា លេខទូរស័ព្ទ អាស័យដ្ឋាន ឬព័ត៌មានហិរញ្ញវត្ថុ) ជាដើម និងមិនគួរផ្សព្វផ្សាយរូបភាព ឬវីដេអូដែលប៉ះពាល់ដល់ឯកជនភាពឬអារម្មណ៍របស់អ្នកដទៃ។ យុវជនគួរចេះជ្រើសរើសមាតិកាដែលមានអត្ថន័យ វប្បធម៌ និងអប់រំ ដែលអាចបង្ហាញខ្លួនជាគំរូល្អក្នុងការចែករំលែក ជាពិសេសជំរុញការរៀនសូត្រ ការអភិវឌ្ឍខ្លួនឯង និងការរួបរួមក្នុងសង្គម ដោយចេះជួយគាំទ្រចំពោះសង្គម ឬសកម្មភាពជាវិជ្ជមានជាតិ ជាពិសេសនាពេលមានសត្រូវឈ្លានពាន យុវជនគួរប្រើបណ្តាញសង្គមប្រកបដោយគុណតម្លៃ ក្នុងស្មារតីរួមគ្នាជាធ្លុងមួយក្នុងការការពារបូរណភាពជាតិរបស់ខ្លួន។

ម្យ៉ាងវិញទៀត យុវជនមិនគួរប្រើបណ្តាញសង្គមដើម្បីបង្កជម្លោះ ឬធ្វើជាល្បែងនយោបាយបំផ្លិចបំផ្លាញជាតិ ពោលគឺមិនចូលរួមក្នុងសកម្មភាពខុសច្បាប់ ក៏ដូចជាការបង្ហោះមាតិកាដែលអាចបង្កការបែកបាក់ ឬធ្វើឱ្យសង្គមកើតការឈ្លោះប្រកែក ឬកើតចលាចល។ យុវជនគួរចងចាំថាប្រសិនបើយុវជនប្រើប្រាស់បណ្តាញសង្គមដោយគោរពតម្លៃខ្លួន តម្លៃអ្នកដទៃ និងតម្លៃវប្បធម៌ខ្មែរ ដោយឈរលើគោលការណ៍ទំនួលខុសត្រូវខ្ពស់ អាចធ្វើឱ្យបណ្តាញសង្គមក្លាយជាវេទិកាវិជ្ជមាន ក្នុងការបង្កើនចំណេះដឹង រក្សាបាននូវស្ថេរភាពជាតិ និងចូលរួមចំណែកក្នុងអភិវឌ្ឍសង្គមជាតិឱ្យបានកាន់តែប្រសើរ ឱ្យកាន់ល្អ រស់ក្នុងភាពសុខដុមរមនា សុខសន្តិភាព និងនាំសង្គមជាតិឈានទៅរកភាពរុងរោចន៍ គួរជាទីមោទនៈនៃសង្គមជាតិយើង៕

យុវជនប្រើបណ្តាញសង្គមបានល្អជាជំហរដ៏រឹងមាំនៃសង្គមជាតិ !